**ក្រសួងកសិកម្ម រុក្ខាប្រមាញ់**
**និងនេសាទ**

**Australian Embassy**
**Cambodia**

# សេចក្តីប្រកាសព័ត៌មានរួម

## កម្ពុជា និង អូស្ត្រាលី ដាក់ឱ្យប្រើប្រាស់ពូជស្រូវក្រអូបថ្មីគឺ ចំប៉ីស៧០

ពូជស្រូវចំប៉ីស៧០ មានវត្តមានជាផ្លូវការ បន្ទាប់ពីប្រើពេលអស់ ៩ឆ្នាំ ក្នុងការស្រាវជ្រាវ និងឆ្លងកាត់ការធ្វើពិសោធនៅលើស្រែកសិករ ចំនួន៨០កន្លែង ។

ពូជស្រូវចំប៉ីស៧០ គឺជាលទ្ធផលនៃកិច្ចសហប្រតិបត្តិការជិតមួយទសវត្សរ៍ រវាងវិទ្យាស្ថានស្រាវជ្រាវ និងអភិវឌ្ឍន៍កសិកម្មកម្ពុជា ហៅកាត់ថា "វ.ស.អ.ក.ក" និងរដ្ឋាភិបាលអូស្ត្រាលី។

ចំប៉ីស៧០ ត្រូវបានបង្កាត់ចេញពីពូជស្រូវផ្ការំដួលរបស់កម្ពុជា ដែលជាស្រូវជាប់ពានរង្វាន់ល្អដាច់គេក្នុងពិភពលោកជាមួយនឹងស្រឡាយស្រូវមិនប្រកាន់រដូវ CNi9024។ ពូជស្រូវនេះបានឆ្លងកាត់ពិសោធន៍នៅលើស្រែកសិករចំនួន៨០កន្លែង ទាំងក្នុងរដូវប្រាំងនិងរដូវវស្សា។ ទិវាស្រែចំនួនបីត្រូវបានរៀបចំដោយមានការចូលរួមពីកសិករប្រមាណជា៩០នាក់ ដែលមួយភាគបីនៃអ្នកចូលរួមគឺជាស្ត្រី ដើម្បីវាយតម្លៃទៅលើស្រឡាយដែលល្អបំផុតសម្រាប់ការបញ្ចេញពូជ។ ស្រឡាយមួយត្រូវបានជ្រើសរើសនិងដាក់ជូនគណៈកម្មការបញ្ចេញពូជដំណាំ នៃក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ។

ថ្ងៃនេះ ឯកឧត្តម Justin Whyatt ឯកអគ្គរាជទូត អូស្ត្រាលីប្រចាំប្រទេសកម្ពុជា និងឯកឧត្តម ឌិត ទីណា រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ បានរួមគ្នាច្រូតស្រូវ និងដាក់ឱ្យប្រើប្រាស់នូវពូជស្រូវចំប៉ីស៧០ ក្នុងទិវាច្រូតស្រូវ ចំប៉ីស៧០ នៅ វ.ស.អ.ក.ក។

ចំប៉ីស៧០ គឺជាពូជស្រូវក្រអូបដែលប្រើពេលត្រឹម៣ខែក្នុងការដាំដុះ។ ស្រូវនេះគឺជាប្រភេទពូជស្រូវមិនប្រកាន់រដូវ ព្រមទាំងធន់នឹងការប្រែប្រួលអាកាសធាតុ ទឹកជំនន់ និងគ្រោះរាំងស្ងួតជាដើម។ កសិករអាចដាំដុះពូជចំប៉ីស៧០ បានពី២ ទៅ៣ដងក្នុង១ឆ្នាំ ដែលនាំឱ្យមានកំណើនផលិតកម្ម និងបរិមាណផល។ ពូជស្រូវប្រភេទថ្មីនេះក៏នឹងរួមចំណែកយ៉ាងសំខាន់ក្នុងការកាត់បន្ថយបន្ទុកដើមទុនសម្រាប់ការដាំដុះ ការចំណាយលើការទុកដាក់ស្រូវ និងការបាត់បង់ក្រោយពេលប្រមូលផល។

លោក ឡោ ប៊ុណ្ណា នាយក វ.ស.អ.ក.ក បានលើកឡើងថា «ពូជស្រូវមួយនេះ ពិតជាមានគុណប្រយោជន៍ខ្លាំងណាស់សម្រាប់កសិករ និងពាណិជ្ជករ។ វាអាចជួយកសិករក្នុងការកាត់បន្ថយការចំណាយ និងកម្លាំងក្នុងការថែទាំស្រែរបស់ពួកគេ។ ដោយសារតែវាជាប្រភេទពូជស្រូវមិនប្រកាន់រដូវ ពាណិជ្ជករអាចទិញស្រូវចំប៉ីស៧០ បានពេញមួយឆ្នាំតែម្តង»។

វិស័យកសិកម្ម គឺជាសសរស្តម្ភដ៏សំខាន់មួយនៃសេដ្ឋកិច្ចកម្ពុជា ដែលរួមចំណែកជិតមួយភាគបួននៃផលិតផលក្នុងស្រុកសរុបរបស់កម្ពុជាក្នុងឆ្នាំ២០២១។ វិស័យនេះផ្តល់ការងារជាងមួយភាគបីនៃចំនួនការងារសរុបរបស់កម្ពុជា ដែលច្រើនជាងពាក់កណ្តាលនៃអ្នកធ្វើការសរុប គឺជាស្ត្រី។

អង្ករក្រអូប មានតម្រូវការខ្ពស់នៅទូទាំងពិភពលោក ដែលការនាំចេញមានចំនួនច្រើនជាង៦០ភាគរយ នៃអង្ករនាំចេញសរុបរបស់កម្ពុជា។ សហព័ន្ធស្រូវអង្ករកម្ពុជា បានដាក់គោលដៅនាំចេញអង្ករឱ្យបាន១លានតោនក្នុងឆ្នាំ២០២៥ខាងមុខ។

ឯកឧត្តម ឌិត ទីណា រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ បានមានប្រសាសន៍ថា៖ «ចំប៉ីស៧០ ត្រូវបានដាក់ឈ្មោះដោយ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា** ក្នុងន័យអបអរសាទរខួប៧០ឆ្នាំនៃទំនាក់ទំនងការទូតដ៏សំខាន់ រវាងប្រទេសកម្ពុជា និងប្រទេសអូស្ត្រាលី ។ ពូជស្រូវថ្មីមួយនេះ នឹងរួមចំណែកយ៉ាងសំខាន់ក្នុងដំណើរការពិពិធកម្មផលិតកម្មអង្ករក្រអូប និងការនាំចេញអង្ករក្រអូបទៅកាន់ទីផ្សារអន្តរជាតិ ដែលធ្វើឱ្យជីវភាពរបស់ប្រជាកសិករកម្ពុជាកាន់តែប្រសើរឡើង»។

ឯកអគ្គរាជទូតអូស្ត្រាលីប្រចាំកម្ពុជា ឯកឧត្តម Justin Whyatt បានលើកឡើងថា «ប្រទេសអូស្ត្រាលីមានមោទកភាពដែលបានគាំទ្រក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងវិទ្យាស្ថានស្រាវជ្រាវ និងអភិវឌ្ឍន៍កសិកម្មកម្ពុជា ក្នុងការបង្កើតពូជស្រូវចំប៉ីស៧០នេះ។ ខ្ញុំសង្ឃឹមថា កសិករទូទាំងប្រទេសកម្ពុជា នឹងដាំដុះពូជស្រូវចំប៉ីស៧០នេះ ដើម្បីផ្គត់ផ្គង់ ទីផ្សារក្នុងស្រុក និងអន្តរជាតិ រួមទាំងទីផ្សារប្រទេសអូស្ត្រាលីផងដែរ»។

ប្រទេសអូស្ត្រាលីគឺជាដៃគូដ៏យូរអង្វែងរបស់កម្ពុជាក្នុងកិច្ចគាំទ្រលើវិស័យកសិកម្មចាប់តាំងពីទសវត្សរ៍ឆ្នាំ១៩៦០ គឺនៅពេលដែលអូស្ត្រាលីបានបញ្ជូនអ្នកជំនាញកសិកម្មមកជួយធ្វើឱ្យប្រសើរឡើងនូវការស្រាវជ្រាវដែលយកដំណាំស្រូវជាមូលដ្ឋាន។ អូស្ត្រាលីក៏បានគាំទ្រលើការងារសំខាន់ៗផ្សេងៗទៀត រួមមានការបង្កើតឡើងនូវវិទ្យាស្ថានស្រាវជ្រាវនិងអភិវឌ្ឍន៍កសិកម្មកម្ពុជាក្នុងឆ្នាំ១៩៩៩ ក្រោមភាពជាដៃគូដ៏រឹងមាំជាមួយមជ្ឈមណ្ឌលអូស្ត្រាលីសម្រាប់ការស្រាវជ្រាវកសិកម្មអន្តរជាតិ និងការដាក់ឱ្យដំណើរការកម្មវិធីខ្សែសង្វាក់តម្លៃកសិកម្មកម្ពុជា (CAVAC) មានរយៈពេល ១២ឆ្នាំ ដែលទើបតែបញ្ចប់ក្នុងឆ្នាំ២០២២។

នៅខែកញ្ញា ឆ្នាំ២០២២ អូស្ត្រាលីបានប្រកាសដាក់ឱ្យដំណើរការកម្មវិធីថ្មីមួយទៀត គឺកម្មវិធីភាពជាដៃគូ កម្ពុជា អូស្ត្រាលីសម្រាប់ការអភិវឌ្ឍសេដ្ឋកិច្ចប្រកបដោយភាពធន់ (CAPRED)។ កម្មវិធីនេះមានគោលបំណងជួយប្រទេសកម្ពុជា ឱ្យសម្រេចបាននូវការអភិវឌ្ឍសេដ្ឋកិច្ចប្រកបដោយនិរន្តរភាព បរិយាបន្ន និងភាពធន់។ សមភាពយេនឌ័រ ពិការភាព និងបរិយាបន្នសង្គម និងភាពធន់នៃបម្រែបម្រួលអាកាសធាតុ ត្រូវបានបញ្ជ្រាបទៅក្នុងគ្រប់សកម្មភាពរបស់កម្មវិធីCAPRED។

ថ្ងៃពុធ ១៥កើត ខែចេត្រ ឆ្នាំខាល ចត្វាស័ក ព.ស ២៥៦៦
រាជធានីភ្នំពេញ ថ្ងៃទី៥ ខែមេសា ឆ្នាំ២០២៣

**សម្រាប់ព័ត៌មានបន្ថែម សូមទំនាក់ទំនង**

- ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ **លោកជំទាវ អ៊ឹម រចនា** អនុរដ្ឋលេខាធិការ នៃក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ: ០៧៧ ៨២៤៤៦៦
- ស្ថានទូតអូស្ត្រាលីប្រចាំនៅប្រទេសកម្ពុជា: Media.Cambodia@dfat.gov.au

Ministry of Agriculture,
Forestry and Fisheries

Australian Embassy

Cambodia

# JOINT PRESS RELEASE

**Date: 5 April 2023**

**Cambodia and Australia launched a new fragrant rice variety, Champei Sar 70**

After nine years and 80 on-farm trials— Champei Sar 70 is officially here!

Champei Sar 70 (CPS 70) is the result of nearly a decade of collaboration between the Cambodian Agricultural Research and Development Institute (CARDI) and the Australian Government.

CPS 70 was developed from an award-winning Cambodian rice variety, Phka Rumduol with CNi9024. There were 80 on-farm trials in both dry and wet seasons, and three farmer participatory events with nearly 90 participants, a third of them are women, to evaluate promising lines. One line was selected and submitted to the National Varietal Release Committee of the Ministry of Agriculture, Forestry and Fisheries (MAFF).

Today, H.E. Justin Whyatt, Australian Ambassador to Cambodia, and H.E. Dith Tina, Minister of MAFF, jointly harvested and launched CPS 70 at the Harvesting Ceremony at CARDI.

CPS 70 is a fragrant rice that matures after three months. It is a non-seasonal crop that is resistant to floods and drought. Farmers can grow CPS 70 two to three times per year, increasing production and output. It will also significantly reduce the burden of working capital, paddy storage cost and post-harvest loss.

“This rice variety is very beneficial for both farmers and traders. It could help farmers cut down on their expenses and efforts to take care of their rice fields. Since it is non-seasonal, traders can buy the paddy all year round,” said Mr Lor Bunna, Director of CARDI.

Agriculture is one of the key pillars of the Cambodian economy, contributing nearly a quarter of total GDP (2021). Agriculture employs over a third of Cambodia’s workers, with more than half of them being women.

Fragrant rice is in high demand globally and accounts for more than 60 per cent of Cambodia’s total milled rice exports. The Cambodia Rice Federation is working towards exporting one million tonnes of milled rice by 2025.

H.E Dith Tina said, “Champei Sar 70 was named by the Prime Minister of Cambodia, Samdech Akka Moha Sena Padei Techo HUN SEN, to mark the important diplomatic relationship between Cambodia and Australia for the

70th anniversary. This new variety will significantly contribute to the diversification of fragrant rice production and the export of fragrant rice to international markets, leading to the improvement of farmers' livelihoods."

"Australia is very proud to have supported MAFF and CARDI on the development of Champei Sar 70. I hope that farmers across Cambodia will grow CPS 70 to supply local and international markets, including Australia," said Ambassador Whyatt.

Australia has been a long-standing supporter of Cambodia's agriculture sector since the 1960s when it started sending agricultural experts to improve rice-based research. Other key support includes the establishment of CARDI in 1999, a strong partnership with the Australian Centre for International Agricultural Research (ACIAR), and the 12-year Cambodia-Australia Agricultural Value Chain Program (CAVAC), which concluded in 2022.

In September 2022, Australia launched its new flagship development program, the Cambodia Australia Partnership for Resilient Economic Development (CAPRED). Its aim is to help Cambodia achieve sustainable, inclusive and resilient economic growth. Gender equality, disability and social inclusion (GEDSI) and climate resilience are integrated into all CAPRED activities.

**Media enquiries**:


- Ministry of Agriculture, Forestry and Fisheries:

  **H.E. Rachana Im**, Under Secretary of State: 077824466

- Australian Embassy: Media.Cambodia@dfat.gov.au